ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*ឯកសារជំនួយស្មារតី*

ស្តីពី

# “ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ”

រៀបរៀងដោយ :

**លោក ស៊ុន លៀងហេង**

© រក្សាសិទ្ធិគ្រប់យ៉ាង ២០១៥

**បណ្ណាល័យច្បាប់**-Law Library (lawlibrarysite.wordpress.com)

# ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ

*(មាត្រា ៥២៤ និងមាត្រា ៥២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)*

រៀបរៀងដោយ: លោក **ស៊ុន លៀងហេង**

| ល.រ | ប្លង់ | សេចក្តីពន្យល់/សេចក្តីបកស្រាយ |
|---|---|---|
| | | **I. សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ** |
| ០១ | សិទ្ធិទាមទារ | **ក.សិទ្ធិប្រត្យក្ស**<br>• សិទ្ធិទាមទារឲ្យប្រគល់មកវិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ (មាត្រា ១៥៥ នៃក្រមរដ្ឋប្បវេណី)។<br>• សិទ្ធិទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ (មាត្រា ២៣៧ នៃក្រមរដ្ឋប្បវេណី)<br>• សិទ្ធិទាមទារឲ្យប្រគល់មកវិញដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់អ្នកជួលអចិន្ត្រៃយ៍ (មាត្រា២៥៣ នៃក្រមរដ្ឋប្បវេណី)<br>• សិទ្ធិទាមទារឲ្យប្រគល់មកវិញដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់ផលុបភោគី (មាត្រា២៦៥ នៃក្រមរដ្ឋប្បវេណី)<br>• សិទ្ធិទាមទារឲ្យប្រគល់មកវិញដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់ម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ (មាត្រា២៨១ នៃក្រមរដ្ឋប្បវេណី)<br>• សិទ្ធិទាមទារឲ្យប្រគល់មកវិញដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់ម្ចាស់សេវភាព (មាត្រា២៩៤ នៃក្រមរដ្ឋប្បវេណី)<br>• សិទ្ធិទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ របស់ម្ចាស់សិទ្ធិឃាត់ទុក (មាត្រា៧៨០ កថាខណ្ឌទី២ និងមាត្រា ២៣៧ នៃក្រមរដ្ឋប្បវេណី)<br>• ការប្រគល់វត្ថុបញ្ចាំ (មាត្រា ៨១៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) |

| | | |
|---|---|---|
| | | **ខ.សិទ្ធិលើបំណុល**<br>• ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុ ដោយផ្អែកលើកិច្ចសន្យាលក់ទិញ (មាត្រា ៥៤៩ នៃក្រមរដ្ឋប្បវេណី)<br>• សិទ្ធិទាមទារឲ្យប្រគល់វិញ របស់ភតិក:ដែលកំពុងកាន់កាប់វត្ថុជួល (មាត្រា ៥៩៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)<br>• ករណីយកិច្ចប្រគល់វត្ថុជួល (មាត្រា ៦១៨ នៃក្រមរដ្ឋប្បវេណី)<br>• ករណីយកិច្ចប្រគល់វត្ថុខ្ចី (មាត្រា ៦៣៤ នៃក្រមរដ្ឋប្បវេណី)<br>• ករណីយកិច្ចសងវត្ថុបញ្ញើ (មាត្រា៦៨២ នៃក្រមរដ្ឋប្បវេណី)<br>• ករណីយកិច្ចសងវត្ថុដែលជាកម្មវត្ថុនៃវិវាទ របស់វិសុណ្ឌាបនិក (មាត្រា ៦៩៦ នៃក្រមរដ្ឋប្បវេណី)។<br>• ជាអាទិ៍..................... |
| ០២ | កម្មវត្ថុ | **ក. អចលនវត្ថុ៖** សំដៅទៅលើ ដីធ្លី និង វត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជា អាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍ (មាត្រា ១២០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។<br>**ខ. នាវា៖** សំដៅលើជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និង លើសពី ២០ តោន ទោះបីមិនបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ និង ជលយានដែលមានចំណុះសរុបជាតោន ក្រោម ២០ តោនដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា (មាត្រា ៤៥៤ កថាខណ្ឌទី១)។<br>**គ. វត្ថុផ្សេងទៀតដែលមានមនុស្សរស់នៅ៖** សំដៅលើចលនវត្ថុដែលមិនមែនជាសមាសភាគនៃដី ហើយមានមនុស្សរស់នៅក្នុងវត្ថុនោះ ដូចជា រថយន្តសម្រាប់ហោះជំរុំ ផ្ទះចល័ត ជាអាទិ៍ ដែលមនុស្សរស់នៅក្នុងនោះ។ |
| ០៣ | ស្ថាប័នអនុវត្ត | ជាគោលការណ៍ ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត ដែលស្ថាប័នការអនុវត្ត រួមមាន តុលាការអនុវត្ត និង អាជ្ញាសាលា (មាត្រា ៣៣៦ កថាខណ្ឌទី១ និងទី២)។ ដោយឡែកចំពោះការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ជាអាទិ៍ នេះ គឺស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តស្ថិតនៅ (មាត្រា ៥២៤ កថាខណ្ឌទី១)។ |

| II. លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ | | |
|---|---|---|
| ០១ | លិខិតអនុវត្ត | ជាគោលការណ៍ ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី១)។ ដោយសារការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺជាស្ថិតនៅក្នុងប្រភេទនៃការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឱ្យសងជាប្រាក់ ហេតុដូច្នេះ លិខិតអនុវត្ត ដែលអាចក្លាយជាមូលដ្ឋាននៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុបានរួមមាន៖<br>ក.សាលក្រមឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ។<br>ខ. សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។<br>គ. ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក ។ ប៉ុន្តែចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរ។<br>ឃ. សាលក្រម ឬ សាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្តដែលបានចូលជាស្ថាពរ តាមបញ្ញត្តិមាត្រា ៣៥២ (សាលក្រមអនុវត្តសាលក្រម ឬ សាលដីការបស់តុលាការបរទេស ជាអាទិ៍)<br>ង. សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរតាមបញ្ញត្តិនៃមាត្រា ៣៥៣ (ដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ)។<br>ច. កំណត់ហេតុដែលបានកំណត់នៅក្នុងមាត្រា ២២២ (អានុភាពនៃកំណត់ហេតុសះជា ជាអាទិ៍) និងកំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ។ |
| ០២ | រូបមន្តអនុវត្ត | ជាគោលការណ៍ ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត (មាត្រា ៣៥៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១)។ រូបមន្តអនុវត្តដែលត្រូវភ្ជាប់មកជាមួយនូវ ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត អាចជារូបមន្តអនុវត្តធម្មតា ឬ រូបមន្តអនុវត្តពិសេស អាស្រ័យទៅតាមខ្លឹមសារនៃលិខិតអនុវត្ត ឬ បុគ្គលដែលត្រូវអនុវត្ត (មាត្រា ៣៥៤ និង មាត្រា ៣៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ |

| | | |
|---|---|---|
| ០៣ | ពាក្យសុំឲ្យអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ | ជាគោលការណ៍ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត តាមពាក្យសុំរបស់ភាគី (មាត្រា ៣៣៦ កថាខណ្ឌទី១)។ ការសរសេរពាក្យសុំអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដែលក្នុងនោះម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរសំខាន់ៗ (មាត្រា៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូចខាងក្រោម៖<br>- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។<br>- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។<br>- សញ្ញាណនៃលិខិតអនុវត្ត<br>- សេចក្តីសុំឲ្យអនុវត្ត៖ សុំឲ្យអនុវត្តដោយបង្ខំឲ្យប្រគល់ដោយផ្ទាល់<br>- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត៖ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវរៀបរាប់នូវអត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត។ |
| **III. ការរៀបចំដាក់ និង ពិនិត្យពាក្យសុំឲ្យសុំឲ្យអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ** | | |
| ០១ | ការចរចា និង ការស្រាវជ្រាវ | ជាធម្មតា ម្ចាស់បំណុលនៃការអនុវត្ត តែងតែងចង់ឲ្យកូនបំណុលនៃការអនុវត្ត ធ្វើការអនុវត្តដោយស្ម័គ្រចិត្តជាមុនសិន ក្នុងគោលបំណងទទួលបាននូវផលចំណេញច្រើនដូចជា ប្រាក់កាស ពេលវេលា ជាដើម។ បើគ្មានការអនុវត្តដោយស្ម័គ្រចិត្តរបស់កូនបំណុលនៃការអនុវត្តទេ ទើបម្ចាស់បំណុលនៃការអនុវត្ត ចាប់ផ្តើមឲ្យស្វែងជំនួយពីស្ថាប័នអនុវត្ត ដែលមានសមត្ថកិច្ច ដើម្បីសម្រេចនូវសិទ្ធិទាមទារឲ្យប្រគល់អចលនវត្ថុ ដែលមានកំណត់នៅក្នុងលិខិតអនុវត្ត។<br>នៅមុននឹងការចាប់ផ្តើមការអនុវត្តដោយបង្ខំ ម្ចាស់បំណុលនៃការអនុវត្ត គប្បីធ្វើការស្រាវជ្រាវជាមុនអំពីចំណុចសំខាន់ៗ មួយចំនួន ដើម្បីបង្កលក្ខណៈងាយស្រួលដល់អាជ្ញាសាលា ដែលជាស្ថាប័នអនុវត្ត ដូចជា អ្នកកាន់កាប់អចលនវត្ថុ ទីតាំងភូមិសាស្ត្រ ទំហំនៃការអនុវត្ត ស្ថានភាពនៃវត្ថុនដែលជាកម្មវត្ថុនៃការអនុវត្ត ជាដើម ។ល។ |

| | | |
|---|---|---|
| ០២ | ការសរសេរពាក្យសុំ | ដើម្បីចាប់ផ្តើមការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុនោះ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរពាក្យសុំឱ្យអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាលាយលក្ខណ៍អក្សរ (មាត្រា ៣៤៩ កថាខណ្ឌទី១) ដែលក្នុងនោះ ត្រូវសរសេរនៅចំណុចសំខាន់ៗ ដូចខាងក្រោម៖<br>• ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត ព្រមទាំងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។<br>• ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត ព្រមទាំងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។<br>• សេចក្តីស្នើសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់។<br>• សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង វិធីនៃការអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។ |
| ០៣ | ការដាក់ពាក្យសុំ | បន្ទាប់ពីពាក្យសុំត្រូវបានសរសេររួចរាល់ហើយ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវរៀបចំនូវឯកសារសម្រាប់ភ្ជាប់ជាមួយនឹងពាក្យសុំ នៅមុនពេលដាក់ទៅកាន់ស្ថាប័នអនុវត្ត ដែលឯកសារទាំងនោះ រួមមាន៖<br>• លិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី២)<br>• លិខិតបញ្ជាក់ការចូលជាស្ថាពរនៃលិខិតអនុវត្ត ប្រសិនបើលិខិតអនុវត្តនោះជាសេចក្តីរបស់តុលាការដែលមានអានុភាពអនុវត្ត លុះត្រាតែបានចូលជាស្ថាពរ ដែលត្រូវបញ្ជាក់ក្រឡាបញ្ជីនៃសំណុំរឿង។<br>• រូបមន្តអនុវត្ត (មាត្រា ៣៥៤) អាចជារូបមន្តធម្មតា ឬ រូបមន្តអនុវត្តពិសេស ដែលចេញដោយ ក្រឡាបញ្ជី ឬ សាការី។<br>• លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ប្រសិនបើពាក្យសុំត្រូវធ្វើឡើងដោយ មេធាវីតំណាងដោយអាណត្តិ។<br>បន្ទាប់មក ម្ចាស់បំណុលនៃការអនុវត្ត ត្រូវយកពាក្យសុំឱ្យអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ និង ឯកសារភ្ជាប់ នៅទៅដាក់នៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ។<br>ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបង់ពន្ធដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំនួន ៥,០០០ រៀល (មាត្រា ៣៧២ កថាខណ្ឌទី២)។ |

| | | |
|---|---|---|
| ០៤ | ការពិនិត្យពាក្យសុំ | បន្ទាប់ពីទទួលបានពាក្យសុំឲ្យអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុរួចហើយ អាជ្ញាសាលា ត្រូវធ្វើការពិនិត្យពាក្យសុំដូចខាងក្រោម៖<br>• តើអាជ្ញាសាលាមានសមត្ថកិច្ចលើការអនុវត្តនេះដែរឬទេ?<br>• តើពាក្យសុំបានបំពេញនូវលក្ខខណ្ឌត្រឹមត្រូវ តាមមាត្រា ៣៤៩ និងមាត្រា ៥២៤?<br>• តើភាគីនៅក្នុងពាក្យសុំឲ្យអនុវត្តដោយបង្ខំ និង ភាគីនៅក្នុងលិខិតអនុវត្តនោះត្រឹមត្រូវនិងដូចគ្នាដែរឬទេ?<br>• តើមានឯកសារភ្ជាប់គ្រប់គ្រាន់ដែរឬទេ?<br>• តើពេលកំណត់ពិតប្រាកដនៃសិទ្ធិទាមទារ ដែលបានកំណត់ក្នុងលិខិតអនុវត្តបានមកដល់ឬនៅ? (មាត្រា ៣៦១ កថាខណ្ឌទី១)<br>• តើមានលិខិតបញ្ជាក់អំពីការដាក់ប្រាតិភោគដែរឬទេ? (មាត្រា ៣៦១ កថាខណ្ឌទី២)<br>• តើមានការបញ្ជាក់អំពីការដាក់តាវកាលិកតប ឬ មានការស្នើដាក់តាវកាលិកតបដែរឬទេ? (មាត្រា ៣៦១ កថាខណ្ឌទី៣)?<br>• តើបានបង់ពន្ធលើពាក្យសុំឲ្យអនុវត្តតាមបញ្ញត្តិនៃមាត្រា ៣៧២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង ប្រការ ១៣ នៃប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាដែរឬទេ?<br>• តើបញ្ជូនទៅកូនបំណុលនៃអនុវត្ត នូវលិខិតអនុវត្ត រូបមន្តអនុវត្តពិសេស ឬ រូបមន្តអនុវត្តច្រើនច្បាប់ដែរឬទេ? (មាត្រា៣៦០ មាត្រា២៤៦ ..)<br>• តើម្ចាស់បំណុលបានបង់សោហ៊ុយជាមុនហើយឬនៅ? (ម.៣៥ នៃសេចក្តីព្រាងច្បាប់ និង ប្រការ ១៥) |
| **IV. វិធីអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ** | | |
| ០១ | ករណីអចលនវត្ថុកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត | • វិធីអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុនេះ គឺអាជ្ញាសាលា ត្រូវធ្វើការរំលាយការកាន់កាប់អចលនវត្ថុដែលជាកម្មវត្ថុរបស់កូនបំណុលនៃការអនុវត្ត ហើយធ្វើឲ្យម្ចាស់បំណុលនៃការអនុវត្តទទួលបាននូវការកាន់កាប់នោះ (មាត្រា ៥២៤ កថាខណ្ឌទី១)។<br>• ដើម្បីសម្រេចបានតាមគោលបំណងនេះ អាជ្ញាសាលា ត្រូវបង្គាប់ឲ្យកូនបំណុលនៃការអនុវត្ត ជាអាទិ៍ ឲ្យចាកចេញ ហើយប្រសិនបើពួកគេមិនព្រមចេញតាមការបង្គាប់ទេនោះ អាជ្ញាសាលា អាចប្រើកម្លាំង ឬ អាចសុំជំនួយគេនគរបាលបាន ប្រសិនបើចាំបាច់ (មាត្រា ៣៣៨ កថាខណ្ឌទី១)។ ប៉ុន្តែដើម្បីធ្វើការអនុវត្តចំពោះបុគ្គលដែលត្រូវទទួលស្គាល់ថា កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយឯករាជ្យដាច់ដោយឡែកពីកូនបំណុលនៃការអនុវត្ត (បុគ្គលដែលមិនមែនជាសមាជិកគ្រួសាររបស់កូនបំណុលនៃការអនុវត្ត ជាអាទិ៍) ដូចជា អ្នកជួល ជាដើម នោះចាំបាច់ត្រូវតែមានលិខិតអនុវត្តចំពោះបុគ្គលនោះ ។ |

| | | |
|---|---|---|
| | | • ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុនេះ អាចធ្វើបានលុះត្រាតែ ម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់ម្ចាស់បំណុលនៃការអនុវត្តនោះ បានបង្ហាញខ្លួននៅកន្លែងអនុវត្ត (មាត្រា៥២៤ កថាខណ្ឌទី២)។ មូលដ្ឋានដែលកំណត់ដូច្នេះ ដោយហេតុថា ទោះបីជាអាជ្ញាសាលា បានរំលាយការកាន់កាប់អចលនវត្ថុដែលកម្មវត្ថុនៃការអនុវត្តឱ្យប្រគល់ក៏ដោយ ក៏គោលបំណងនៃការអនុវត្តឱ្យប្រគល់អចលនវត្ថុពុំទាន់បានបញ្ចប់ដែរ ពោលគឺទាល់តែម្ចាស់បំណុលនៃការអនុវត្ត ទទួលបាននូវការកាន់កាប់អចលនវត្ថុ ទើបគោលបំណងនៃការអនុវត្តនេះ បានបញ្ចប់។ នេះជាលក្ខខណ្ឌដាច់ខាតដែលតម្រូវឱ្យមានវត្តមានរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងដើម្បីសម្រេច នូវគោលបំណងនៃការអនុវត្តនេះបាន។ ប្រសិនបើគ្មានវត្តមានរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់ម្ចាស់បំណុលនៃការអនុវត្តទេ អាជ្ញាសាលា មិនអាចចាប់ផ្ដើមការអនុវត្តបានទេ ពោលគឺអាជ្ញាសាលា អាចធ្វើការព្យួរការអនុវត្តដោយលើកពេលនៃការអនុវត្តទៅថ្ងៃក្រោយបាន ។<br>• ដើម្បីឱ្យសម្រេចនូវគោលបំណងនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុនេះ អាជ្ញាសាលា អាចចូលទៅក្នុងអចលនវត្ថុ នាវា ឬ វត្ថុផ្សេងទៀតដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តបាន ហើយបើចាំបាច់ អាជ្ញាសាលា អាចធ្វើការចាត់ចែងជាចាំបាច់ដើម្បីបើកទ្វារដែលបិទនោះ (មាត្រា ៥២៤ កថាខណ្ឌទី៣)។ |
| ០២ | ករណីមានចលនវត្ថុនៅជាមួយនឹងអចលនវត្ថុដែលជាកម្មវត្ថុ | នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ដែលមានចលនវត្ថុនៅជាប់ជាមួយនឹង អចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត តើអាជ្ញាសាលា ត្រូវចំណាត់ការនីតិវិធីយ៉ាងដូចម្ដេច? តើចលនវត្ថុប្រភេទណាដែលត្រូវប្រគល់ឱ្យទៅម្ចាស់បំណុលនៃការអនុវត្ត ហើយចលនវត្ថុប្រភេទណាដែលត្រូវប្រគល់ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ?<br>អនុលោមតាមបញ្ញត្តិនៃមាត្រា៥២៤ កថាខណ្ឌទី៤ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់ថា នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ អាជ្ញាសាលា ត្រូវដកចេញនូវចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះ ទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ ញាតិនៅជាមួយ ឬ អ្នកបម្រើ ឬ អ្នកផ្សេងដែលបានធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យ។<br>តាមស្មារតីនៃមាត្រាខាងលើនេះ អាចធ្វើការកំណត់បានថា តើចលនវត្ថុណាដែលជាកម្មវត្ថុនៃការអនុវត្ត និងចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃការអនុវត្ត? |

**ក. ចលនវត្ថុដែលជាកម្មវត្ថុ និង ចលនវត្ថុដែលជាមិនមែនជាកម្មវត្ថុ**

- **ចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត៖** បើគ្រាន់តែឮថា ចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត អាចឱ្យយើងប៉ាន់ស្មានបានថា ជាចលនវត្ថុដែលមានកំណត់ក្នុងលិខិតអនុវត្ត (ឧទាហរណ៍ដូចជា សាលក្រមដែលបង្គាប់ឱ្យប្រគល់រថយន្ត ជាអាទិ៍) ឬ ចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ (ឧទាហរណ៍ដូចជា សាលក្រមបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តបងប្រាក់កម្ចី ហើយម្ចាស់បំណុលអាចយកសាលក្រមនេះ ទៅអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដោយធ្វើការរឹបអូសចលនវត្ថុទាំងឡាយដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ជាអាទិ៍)។ ដូច្នេះតាមន័យនេះ ចលនវត្ថុដែលជាកម្មវត្ថុ នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ អាចមានន័យថា នៅក្នុងលិខិតអនុវត្តតែមួយតែមានខ្លឹមសារឱ្យប្រគល់អចលនវត្ថុផង និង ប្រគល់ចលនវត្ថុផង (ឧទាហរណ៍ ដូចជា សាលក្រមបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តប្រគល់អចលនវត្ថុ និងប្រគល់រថយន្ត ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។ បើតាមខ្លឹមសារនេះ គឺនឹងមិនមានបញ្ហាចោតអ្វីឡើងដល់ការអនុវត្ត ថាតើគួរអនុវត្តរបៀបណា។ ចុះប្រសិនបើចលនវត្ថុនោះជាមិនមានកំណត់ក្នុងលិខិតអនុវត្ត តែមិនអាចដកចេញ ឬ បំបែកបាន ហើយបើដកចេញ ឬ បំបែកចេញនោះ វានឹងធ្វើឱ្យខូចទ្រង់ទ្រាយអាគារ ឬ លក្ខណៈដើមនៃវត្ថុនោះ តើចលនវត្ថុនេះ ត្រូវដកឱ្យទៅកូនបំណុលនៃការអនុវត្ត ឬ ចាត់ទុកជាកម្មវត្ថុនៃការអនុវត្តដែរ ឬ មិនធ្វើការដកចេញទេ? ចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ក៏សំដៅផងដែរ សមាសភាគនៃវត្ថុ ឬ សមាសភាគនៃអាគារ ដូចជា គ្រឿងអាគារ គ្រឿងសង្ហារិម ផ្ទាំកវត្ថុតុបតែង ជាអាទិ៍ដែលមិនអាចបំបែកបានពីអាគារ (មាត្រា ១២៥ នៃក្រមរដ្ឋប្បវេណី) ដែលសមាសភាគនៃវត្ថុ ឬ សមាសភាគនៃអាគារនេះ មិនចាំបាច់ធ្វើការដកចេញដើម្បីប្រគល់ឱ្យទៅកូនបំណុលនៃការអនុវត្តទេតាមបញ្ញត្តិនៃមាត្រា ៥២៤ កថាខណ្ឌទី៤ វាក្យខណ្ឌទី១ ទេ ពោលគឺត្រូវប្រគល់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដោយហេតុថា ប្រសិនបើ សមាសភាគនៃវត្ថុ ឬ អាគារនោះ ត្រូវដកចេញ នឹងធ្វើឱ្យប្តូរលក្ខណៈដើម ឬ ខូចទ្រង់ទ្រងនៃវត្ថុនោះ។

- **ចលនវត្ថុដែលមិនមែនជាកម្មវត្ថុ៖** សំដៅដល់ចលនវត្ថុដែលមិនមានកំណត់ក្នុងលិខិតអនុវត្ត ឬ មិនមែនជាសមាសភាគនៃអាគារ ឬ សមាសភាគនៃវត្ថុ ដែលករណីនេះអាជ្ញាសាលា អាចធ្វើការដកចេញនូវវត្ថុទាំងនោះ រួចប្រគល់ឱ្យកូនបំណុលនៃការអនុវត្តបាន។ ចលនវត្ថុនោះ អាចជា វត្ថុចំណុះ ដែលសម្រាប់ធ្វើការបង្កើតសេដ្ឋកិច្ចនៃវត្ថុចម្បង ដូចជា តុ ទូ គ្រែ ជាអាទិ៍ (មាត្រា ១២៧ នៃក្រមរដ្ឋប្បវេណី)។

**ខ. វិធីអនុវត្តចំពោះចលនវត្ថុទាំងនោះ**

- **ចំពោះចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃការអនុវត្ត៖** អាជ្ញាសាលា ត្រូវដកចេញ ហើយត្រូវប្រគល់ចលនវត្ថុនោះទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកតំណាងរបស់កូនបំណុលនៃការអនុវត្ត ឬ ញាតិដែលរស់នៅជាមួយ ឬ អ្នកបម្រើ ឬ អ្នកផ្សេងដែលធ្វើការនោះទីនោះដែលមានការយល់ដឹងសមរម្យ (មាត្រា ៥២៤ កថាខណ្ឌទី៤ វាក្យខណ្ឌទី១)។ ក្នុងករណីនេះ ប្រសិនបើមិនអាចប្រគល់ចលនវត្ថុទាំងនោះទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកតំណាង ឬ ញាតិរបស់កូនបំណុលនៃការអនុវត្តទេនោះ ត្រូវថែរក្សាគ្រប់គ្រងចលនវត្ថុនោះតាមវិធីសមរម្យ ដោយឱ្យកូនបណុលនៃការអនុវត្ត ចេញសោហ៊ុយសម្រាប់ការថែរក្សាគ្រប់គ្រងនេះ (មាត្រា ៥២៤ កថាខណ្ឌទី៤ វាក្យខណ្ឌទី២ និង មាត្រា ៥២៤ កថាខណ្ឌទី៥) ហើយត្រូវធ្វើការជូនដំណឹងនោះទៅឱ្យកូនបំណុលនៃការអនុវត្ត (មាត្រា ៥២៤ កថាខណ្ឌទី៨)។ ប្រសិនបើមិនអាចប្រគល់ចលនវត្ថុនេះទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកតំណាង ឬ ញាតិរបស់កូនបំណុល ឬ អ្នកបម្រើ ឬអ្នកផ្សេងដែលរស់នៅជាមួយនឹងកូនបំណុលនៃការអនុវត្ត ដែលមានការយល់ដឹងសមរម្យបានទេ អាជ្ញាសាលា អាចលក់ចលនវត្ថុនោះ តាមវិធីលក់ចលនវត្ថុដែលបានកំណត់ក្នុងមាត្រា ៣៩៥ នោះបាន។ ហើយក្នុងករណីនេះ អាជ្ញាសាលា ត្រូវដកចេញពីចំនួនទឹកប្រាក់ដែលបានមកពីការលក់នូវសោហ៊ុយដែលបានចំណាយក្នុងការលក់ និង សោយហ៊ុយក្នុងការថែរក្សាគ្រប់គ្រង ហើយត្រូវផ្ញើប្រាក់ដែលនោះសល់នោះទៅសាលាដំបូងដែលខ្លួនស្ថិតនៅ (មាត្រា ៥២៤ កថាខណ្ឌទី៦ និង កថាខណ្ឌទី៧)។ ដោយសារថាចលនវត្ថុនោះ មិនមែនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំទេនោះ តតិយជន មិនអាចធ្វើការអះអាងអំពីកម្មសិទ្ធិលើចលនវត្ថុនោះ មោនអាចដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន និង មិនអាចទប់ស្កាត់វិធានការណ៍របស់អាជ្ញាសាលាបានឡើយ។

- ចំពោះចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត៖ អាជ្ញាសាលា មិនចាំបាច់ដកចេញនូវចលនវត្ថុនោះទេ ពោលគឺប្រគល់ទាំងចលនវត្ថុ និង អចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។

| | | |
|---|---|---|
| ០៣ | ករណីមានសំណង់ដែលបានសង់នៅលើអចលនវត្ថុដែលជាកម្មវត្ថុ | • ប្រសិនបើមានសំណង់ណាមួយដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ស្ថិតនៅលើដីដែលត្រូវបណ្តេញចេញ ឬ ដីដែលជាកម្មវត្ថុនៃការអនុវត្ត អាជ្ញាសាលា មិនអាចរុះរើសំណង់នោះដោយគ្មានការអនុញ្ញាតបានទេ ដោយហេតុថា នៅក្នុងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត ដែលមានខ្លឹមសារឱ្យប្រគល់អចលនវត្ថុ គឺពុំមានខ្លឹមសារឱ្យធ្វើសកម្មភាពរុះរើទេ ហេតុដូច្នេះ ដើម្បីអាចឱ្យរុះរើសំណង់ដែលបានសង់នៅលើដីដែលជាកម្មវត្ថុនៃការអនុវត្ត នោះបាន គឺត្រូវទាមទារឱ្យមានលិខិតអនុវត្តផ្សេងទៀត ដែលមានខ្លឹមសារឱ្យរុះរើ។<br>• ដូច្នេះ ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ដែលមានសំណង់នៅលើដីដែលជាកម្មវត្ថុ អាជ្ញាសាលា ពុំអាចធ្វើការរុះរើសំណង់នោះបានទេ ពោលគឺបានត្រឹមតែធ្វើការរំលាយការកាន់កាប់អចលនវត្ថុនោះ រួចធ្វើការប្រគល់ការកាន់កាប់អចលនវត្ថុនោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្តតែប៉ុណ្ណោះ។<br>• ដើម្បីអាចឱ្យអាជ្ញាសាលា ធ្វើការរុះរើនូវសំណង់ដែលបានសង់នៅលើដីដែលជាកម្មវត្ថុនៃការអនុវត្តបាន លុះត្រាតែមានលិខិតអនុវត្តផ្សេងទៀត ដែលមានខ្លឹមសារបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តរុះរើ សំណង់នោះចេញ។ ជាគោលការណ៍ ដើម្បីអាចទទួលបាននូវលិខិតអនុវត្ត ដែលមានខ្លឹមសារឱ្យកូនបំណុលនៃការអនុវត្តធ្វើការរុះរើនោះ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវប្រើសិទ្ធិពឹកពាក់តុលាការ ដោយដាក់ពាក្យបណ្តឹងអង្គសេចក្តី ដើម្បីទទួលបាននូវសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក ជាមុនសិន ទើបយកសាលក្រមនោះ ទៅអនុវត្តដោយបង្ខំ ដោយប្រើវិធីអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល តាមបញ្ញត្តិនៃមាត្រា ៥២៧ និង មាត្រា ៥២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។<br>• ប៉ុន្តែដើម្បីទទួលបាននូវភាពឆាប់រហ័ស ម្ចាស់បំណុលនៃការអនុវត្ត អាចប្រើដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលមានខ្លឹមសារឱ្យកូនបំណុល រុះរើសំណង់នោះចេញបាន រួចយកដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ទៅអនុវត្តដូចគ្នានឹងវិធីអនុវត្តដោយបង្ខំ ដោយអនុលោមតាមវិធីអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោលបាន។ |
| ០៤ | ករណីអចលនវត្ថុកាន់កាប់ដោយតតិយជន | **ក. តតិយជនដែលជាបុគ្គលរស់នៅជាមួយ ឬ អ្នកបម្រើ ឬ សាច់ញាតិ ដែលរស់នៅជាមួយនឹងកូនបំណុលនៃការអនុវត្ត**<br>ជាគោលការណ៍ ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ត្រូវធ្វើឡើងចំពោះតែកូនបំណុលនៃការអនុវត្តប៉ុណ្ណោះ ប៉ុន្តែការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ក៏អាចត្រូវបានអនុវត្តផងដែរចំពោះតតិយជនដែលរស់នៅជាមួយនឹងកូនបំណុលនៃការអនុវត្ត ដូចជា អ្នកបម្រើ អ្នកចាំផ្ទះ ឬ សាច់ញាតិដែលរស់នៅជាមួយនឹងកូនបំណុលនៃការអនុវត្ត ជាអាទិ៍។ |

ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុចំពោះតតិយជន ដូចដែលបានរៀបរាប់ខាងលើនេះ ត្រូវបានធ្វើឡើង ដោយគ្រាន់តែផ្អែកលើលិខិតអនុវត្តដែលបានធ្វើឡើងសម្រាប់កូនបំណុលនៃការអនុវត្តប៉ុណ្ណោះ ពោលគឺពុំចាំបាច់តម្រូវឲ្យមានលិខិតអនុវត្តថ្មីផ្សេងទៀត ឬ រូបមន្តអនុវត្តពិសេសតាមបញ្ញត្តិនៃមាត្រា ៣៥៦ កថាខណ្ឌទី២ ឡើយ (មាត្រា ៣៥១ កថាខណ្ឌទី២)។

ប៉ុន្តែការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ដែលធ្វើឡើងចំពោះតតិយជនប្រភេទនេះ ដោយលើលិខិតអនុវត្តដែលមានកំណត់ឈ្មោះកូនបំណុលនៃការអនុវត្តនោះ គឺអាចអនុវត្តបានតែចំពោះលិខិតអនុវត្ត ដូចដែលរៀបរាប់ខាងក្រោម តែប៉ុណ្ណោះ៖

- សាលក្រម ឬ សាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ។
- សាលក្រម ឬ សាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន។
- ដីកាសម្រេចបង្គាប់ឲ្យផ្តល់តាវកាលិក។
- សាលក្រម ឬ សាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្តដែលបានចូលជាស្ថាពរ។
- សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរ។
- កំណត់ហេតុដែលបានកំណត់ក្នុងមាត្រា ២២២។

មូលដ្ឋានដែលអាចអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុចំពោះតតិយជនប្រភេទនេះ ដោយពុំចាំបាច់មានរូបមន្តអនុវត្តពិសេស ឬ លិខិតអនុវត្តផ្សេងទៀត គឺដោយហេតុថា៖

- តតិយជនប្រភេទនេះ កាន់កាប់អចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំឲ្យប្រគល់ គឺដើម្បីផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្តតែប៉ុណ្ណោះ ពោលគឺពុំមានដើម្បីផលប្រយោជន៍ខ្លួនឯងទេ។ ហេតុដូច្នេះ ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុចំពោះតតិយជនប្រភេទនេះ អាចអនុវត្តបានដោយពុំចាំបាច់មានលិខិតអនុវត្តផ្សេងទេ។
- ម្យ៉ាងវិញទៀត នៅក្នុងលិខិតអនុវត្តពុំបានកំណត់យកតតិយជនប្រភេទនេះ មកធ្វើជាភាគីកូនបំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលនៃការអនុវត្ត តាមបញ្ញត្តិនៃមាត្រា ៣៥៦ កថាខណ្ឌទី២ ទេ ហេតុដូច្នេះ ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ក៏ពុំចាំបាច់មានរូបមន្តអនុវត្តពិសេស តាមបញ្ញត្តិនៃមាត្រា ៣៥៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែរ។

ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុចំពោះតតិយជនប្រភេទនេះ គឺត្រូវអនុវត្តតាមនីតិវិធីអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ដែលមានបញ្ញត្តិក្នុងមាត្រា ៥២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីធម្មតា។

**ខ. តតិយជនដែលត្រូវបានយកមកធ្វើជាភាគីនៃការអនុវត្ត**

មាត្រា ៣៥៦ កថាខណ្ឌទី២៖ ដើម្បីធ្វើការអនុវត្តដោយបង្ខំដោយយកបុគ្គលផ្សេង ក្រៅពីភាគីដែលត្រូវបានសរសេរលើលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលការផ្តល់រូបមន្តអនុវត្ត ដែលមានសរសេរនូវហេតុការណ៍នោះ។ ដែលរូបមន្តអនុវត្តនេះ គឺត្រូវតែជារូមមន្តអនុវត្តពិសេស ។

តតិយជននៅក្នុងករណីទីនេះ គឺសំដៅដលតតិយជនដែលមានចែងក្នុងមាត្រា ៣៥១ កថាខណ្ឌទី១ ចំណុច គ ដែលក្នុងនោះ តតិយជននោះ គឺជា អ្នកទទួលបន្តសិទ្ធិ ឬ ករណីយកិច្ចពីបុគ្គលដែលបានកំណត់នៅក្នុងចំណុច ក ឬ ចំណុខ ខ ក្រោយលិខិតអនុវត្ត ត្រូវបានធ្វើឡើង។

តតិយជននោះ គឺសំដៅដល់បុគ្គលដែលបានទទួលបន្តនូវសិទ្ធិ ឬ ករណីយកិច្ចពី ភាគីនៃការអនុវត្ត (ម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត) ឬ ទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចពីបុគ្គលដែលត្រូវបានគេជ្រើសរើសឲ្យធ្វើជាភាគីនៃការអនុវត្ត។ បុគ្គលទាំងនោះ អាចជា សន្តតិជន ឬ អច្ច័យលាភី ជាអាទិ៍។

ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ចំពោះតតិយជនប្រភេទនេះ គឺត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលភ្ជាប់ជាមួយនូវរូបមន្តអនុវត្តពិសេស (មានកំណត់ក្នុងមាត្រា ៣៥៦ កថាខណ្ឌទី២)។ រួចទើប ត្រូវបានអនុវត្តតាមបញ្ញត្តិនៃមាត្រា ៥២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ជាធម្មតា ដែលក្នុងនោះ អាជ្ញាសាលា ត្រូវធ្វើការរំលាយការកាន់កាប់របស់តតិយជនដែលត្រូវបានកំណត់មកធ្វើជាភាគីកូនបំណុលនៃការអនុវត្ត រួចប្រគល់ការកាន់កាប់ឲ្យទៅម្ចាស់បំណុលនៃការអនុវត្ត។

**គ. តតិយជនដែលមានទាមទារឲ្យមានលិខិតអនុវត្តផ្សេងពីលិខិតអនុវត្តដោយដើម/តតិយជនឯករាជ្យ ឬ តតិយជនដែលមានលក្ខខណ្ឌតតាំងនឹងជាម្ចាស់បំណុលនៃការអនុវត្ត**

ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ក៏អាចត្រូវធ្វើឡើងចំពោះតតិយជនដែលមានសិទ្ធិតតាំងជាមួយ នឹងម្ចាស់បំណុលនៃការអនុវត្ត ផងដែរ ឬ អាចហៅម្យ៉ាងទៀតថា តតិយជនឯករាជ្យ។ តតិយជនដែលមានលក្ខខណ្ឌតតាំងជាមួយនឹងម្ចាស់បំណុលនៃការអនុវត្ត គឺសំដៅដល់តតិយជនដែលមាន តតិយជន មួយប្រភេទបុគ្គលដែលកាន់កាប់អចលនវត្ថុដាច់ដោយឡែកពីកូនបំណុលនៃការអនុវត្ត ។ ឬ អាចសំដៅដល់បុគ្គលដែលកាន់កាប់អចលនវត្ថុដោយមានសិទ្ធិតតាំងជាមួយនឹងម្ចាស់បំណុលនៃការអនុវត្ត។

លក្ខខណ្ឌតតាំង សំដៅដល់ លក្ខខណ្ឌមួយដែលទាក់ទងនឹងការផ្សាយជាសារធារណៈនូវការអះអាងនូវសិទ្ធិរបស់ខ្លួន ដែលមានចំពោះម្ចាស់បំណុលនៃការអនុវត្ត។ មានន័យថា បើទោះបីជា នីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ កំពុងចំណាត់ការដោយអាជ្ញាសាលា ក៏ដោយ ក៏អាជ្ញាសាលាពុំអាចអនុវត្តនីតិវិធីរបស់ខ្លួនបាន ដោយផ្អែកតាមលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តត្រឹមកូនបំណុលនៃការអនុវត្ត ប៉ុណ្ណោះទេ ។ ដែលករណីនេះ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវស្វែងរកនូវលិខិតអនុវត្តថ្មីមួយផ្សេងទៀត ដើម្បីអាចអនុវត្តបានចំពោះតតិយជនប្រភេទនេះ។

តើសិទ្ធិអ្វីខ្លះដែលអាចតតាំងជាមួយនឹងម្ចាស់បំណុលនៃការអនុវត្តបាន? ឬ ក៏អាចនិយាយម្យ៉ាងទៀតបានថា តើតតិយជនដែលមានសិទ្ធិអ្វីខ្លះ ដែលត្រូវចាត់ទុកជាតតិយជនប្រភេទនេះបាន?

ដូចដែលបានដឹងហើយថា តតិយជនដែលមានសិទ្ធិតតាំងជាមួយនឹងម្ចាស់បំណុលនៃការអនុវត្ត គឺជាតតិយជនដែលកាន់កាប់អចលនវត្ថុដែលជាកម្មវត្ថុដោយឯករាជ្យពីម្ចាស់បំណុលនៃការអនុវត្ត ហេតុដូច្នេះ យើងអាចកំណត់បានថា តតិយជនប្រភេទនេះ មិនមែនកាន់កាប់អចលនវត្ថុដែលជាកម្មវត្ថុដើម្បីប្រយោជន៍របស់កូនបំណុលនៃការអនុវត្តនោះទេ ។

តតិយជននោះ អាចជា អ្នកជួលផ្ទះ សិទ្ធិប្រើប្រាស់ និង អាស្រ័យនៅ ឬ សិទ្ធិប្រត្យក្សជាអាទិ៍។

**ឃ. តតិយជនដែលមានករណីយត្រូវប្រគល់វត្ថុឱ្យកូនបំណុលនៃការអនុវត្ត ( មាត្រា ៥២៦ )**

តតិយជនកាន់កាប់អចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ហើយតតិយជននោះមានករណីយកិច្ចត្រូវប្រគល់អចលនវត្ថុនោះទៅឱ្យកូនបំណុលនៃការអនុវត្ត។ ឧទាហរណ៍ តតិយជនដែលចូលកាន់កាប់អចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តការអនុវត្តដោយទុច្ចរិត។

ប្រសិនបើមានតតិយជនកំពុងកាន់កាប់វត្ថុដែលជាកម្មវត្ថុន អាជ្ញាសាលា មិនអាចរំលាយការកាន់កាប់របស់តតិយជននោះ ហើយប្រគល់អចលនវត្ថុនោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្តបានដោយផ្ទាល់ទេ។ ប៉ុន្តែប្រសិនបើកូនបំណុលនៃការអនុវត្ត មានសិទ្ធិទាមទារឱ្យប្រគល់ចំពោះតតិយជនដែលកានកាប់នោះ ម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ តាមវិធីដូចការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលទៅតុលាការអនុវត្ត ដើម្បីទទួលបានដីកាសម្រេចរឹបអូសសិទ្ធិទាមទារឱ្យប្រគល់អចលនវត្ថុនោះ និង ដែលអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្ត អាចទាមទារឱ្យប្រគល់នោះចំពោះតតិយជនជំនួសកូនបំណុលនៃការអនុវត្តបាន (មាត្រា ៥២៦)។ នៅក្នុងករណីនេះ តុលាការអនុវត្ត គឺជាសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលលំនៅដ្ឋានរបស់កូនបំណុលនៃការអនុវត្តស្ថិតនៅ(មាត្រា ៥២៦ និង មាត្រា ៤០២ កថាខណ្ឌទី៣)។

| V. សិទ្ធិ និង ករណីយកិច្ចរបស់អាជ្ញាសាលា | | |
|---|---|---|
| ០១ | សិទ្ធិ | • សិទ្ធិប្រើប្រាស់កម្លាំង សុំជំនួយពីនគរបាល ឬ កម្លាំងផ្សេងទៀត (មាត្រា ៣៣៨)៖ នៅក្នុងពេលអនុវត្តកិច្ចការរបស់ខ្លួន អាជ្ញាសាលា អាចប្រើកម្លាំង ឬ ស្នើសុំកម្លាំងនគរបាល ឬ កម្លាំងផ្សេងទៀតបាន។<br>• សិទ្ធិចូលទៅក្នុងអចលនវត្ថុ៖ នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ អាជ្ញាសាលា អាចចូលទៅកាន់អចលនវត្ថុបាន។ (មាត្រា ៥២៤ កថាខណ្ឌទី៣)។<br>• សិទ្ធិបើកទ្វារដែលបិទ៖ បើយល់ថា ចាំបាច់ អាជ្ញាសាលា អាចធ្វើការបើកទ្វារដែលបិទបាន (មាត្រា ៥២៤ កថាខណ្ឌទី៣)។ |
| ០២ | ករណីយកិច្ច | • ការយកទៅជាមួយនឹងអត្តសញ្ញាណប័ណ្ណ នៅពេលបំពេញមុខងារ (មាត្រា ៣៤១)៖ មានន័យថាពេលបំពេញមុខងារ អាជ្ញាសាលា ត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណ ឬ លក្ខណៈសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះចំពោះជនពាក់ព័ន្ធនឹងផលប្រយោជន៍ បើជននោះទាមទារ។<br>• ការអនុវត្តនៅថ្ងៃសម្រាក ឬ ពេលយប់ (មាត្រា ៣៤០)៖ អាជ្ញាសាលា ត្រូវទទួលការអនុវត្តពីសាលាដំបូងដែលខ្លួនស្ថិតនៅ ដើម្បីចូលទៅបំពេញមុខនាទីក្នុងទីកន្លែងរស់នៅ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ ឬ ពីម៉ោងប្រាំមួយល្ងាច ដល់ម៉ោង ប្រាំមួយព្រឹកនៃថ្ងៃបន្ទាប់។ ករណីនេះ អាជ្ញាសាលា ត្រូវបង្ហាញលិខិតអនុញ្ញាតនេះ។<br>• ការស្វែងរកអ្នកសង្កេតការណ៍ (មាត្រា ៣៣៩)៖ នៅពេលចូលទៅដល់ទីកន្លែងរស់នៅដើម្បីបំពេលមុខនាទីរបស់ខ្លួន បើមិនបានជួបនឹងអ្នកចម្បងនៃទីកន្លែងរស់នៅ ឬ អ្នកតំណាងរបស់អ្នកនោះ ឬ ញាតិនៅជាមួយឬអ្នកបម្រើឬអ្នកផ្សេងពីអ្នកដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេ អាជ្ញាសាលា ត្រូវឱ្យមានវត្តមានមន្ត្រីឃុំ សង្កាត់ មន្ត្រីនគរបាល ឬ អ្នកផ្សេងទៀតដែលអាចទទួលស្គាល់ថាជាសាក្សីសមរម្យបាន។<br>• ការតវ៉ាចំពោះការអនុវត្តរបស់អាជ្ញាសាលា (មាត្រា ៣៤៤)៖ ប្រសិនបើការអនុវត្តរបស់អាជ្ញាសាល មានភាពយឺតយ៉ាវ ឬ ខុសនីតិវីធីនោះ ភាគីដែលមានប្រយោជន៍អាចប្ដឹងតវ៉ាចំពោះការអនុវត្តដោយអាជ្ញាសាលា ទៅសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅបាន។<br>• ការថែរក្សា និង ចាត់ចែងចលនវត្ថុដែលនៅជាប់ជាមួយអចលនវត្ថុដែលជាកម្មវត្ថុ (មាត្រា ៥២៤ កថាខណ្ឌទី៤-២ និងកថាខណ្ឌទី៥)៖ ករណីនេះប្រសិនបើមានការដកចេញនូវចលនវត្ថុមួយចំនួនដែលជាប់ជាមួយនូវចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ឬ តតិយជននោះ ហើយ |

| | | |
|---|---|---|
| | | អាជ្ញាសាលា មិនអាចប្រគល់ចលនវត្ថុទាំងនោះ ទៅឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នកតំណាង ឬ ញាតិដែលនៅជាមួយហើយមានការយល់ដឹងសមរម្យទេ អាជ្ញាសាលា ត្រូវរក្សាចលនវត្ថុនោះ ហើយបើនៅតែមិនអាចប្រគល់បានដដែល អាជ្ញាសាលា អាចលក់ចលនវត្ថុនោះ តាមវិធីលក់ចលនវត្ថុ ដែលមានចែងក្នុង មាត្រា ៣៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។<br>• ការធ្វើកំណត់ហេតុៈ គឺជាកត្តាសំខាន់ដែលអាជ្ញាសាលា មិនអាចរំលងបាន ហើយអាជ្ញាសាលា ត្រូវធ្វើកំណត់ហេតុគ្រប់ពេលមានការអនុវត្តទាំងអស់ដូចជា អំឡុងពេលអនុវត្តឱ្យប្រគល់ កំណត់ហេតុលក់ចលនវត្ថុដែលមិនអាចប្រគល់ឱ្យកូនបំណុលបាន កំណត់ហេតុអនុវត្តសាលក្រមមិនបានសម្រេច ជាដើម ។ល។<br>• ករណីយកិច្ចជូនដំណឹងទៅឱ្យកូនបំណុលនៃការអនុវត្ត (មាត្រា ៥២៤ កថាខណ្ឌទី៨)៖ បន្ទាប់ពីបញ្ចប់ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ឬ ការចាត់ចែងលក់ចលនវត្ថុនៅក្នុងនីតិវិធីអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ អាជ្ញាសាលា ត្រូវធ្វើការជូនដំណឹងដល់កូនបំណុលនៃការអនុវត្ត។ |